ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ៨៧៧ ស.ល.គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ៦ ឆ្នាំ២០១៥

# សេចក្ដីជូនដំណឹង

## ស្ដីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការលទ្ធកម្មគម្រោងឃុំ សង្កាត់ ឆ្នាំ២០១៦

លេខាធិការដ្ឋាន គ.ជ.អ.ប មានកិត្តិយសសូមជម្រាបអ្នកទទួលការទាំងអស់ឱ្យបានជ្រាបថា នៅខែកញ្ញា ឆ្នាំ២០១៥ ខាងមុខនេះ រាជធានី ខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៦។ អ្នកទទួលការដែលត្រូវបានបញ្ចូលឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ មានសិទ្ធិដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ នៅគ្រប់ឃុំ សង្កាត់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា ០៣ប្រភេទៈ

**ប្រភេទទី១ៈ** អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អគារ និងការងារបេតុង...។ល។)

**ប្រភេទទី២ៈ** អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រាលក្រួសក្រហម។ល។

**ប្រភេទទី៣ៈ** អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញពិសេសសម្រាប់ការងារពិសេស ដូចជាអណ្ដូងស្នប់...។ល។)

ដូចមានបរិយាយលម្អិតនៅក្នុងពាក្យសុំចុះឈ្មោះ អ្នកទទួលការត្រូវបំពេញព័ត៌មានចាំបាច់ ត្រូវមានបុគ្គលិកបច្ចេកទេស សម្ភារៈនិងបរិក្ខារគ្រប់គ្រាន់ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ និងត្រូវមានបទពិសោធន៍ក្នុងការអនុវត្តគម្រោងទាក់ទងនឹងប្រភេទនីមួយៗ ដែលបានស្នើសុំយ៉ាងតិចចំនួន០២ ក្នុងអំឡុងពេល ០៥ឆ្នាំចុងក្រោយ។ បន្ថែមលើនេះ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងចុះពិនិត្យនិងវាយតម្លៃជាក់ស្ដែងដល់ទីតាំងគម្រោង និងទីតាំងទុកគ្រឿងចក្រ ដើម្បីធានាថាព័ត៌មានទាំងអស់ដែលផ្ដល់ដោយអ្នកទទួលការ ពិតត្រឹមត្រូវ។ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងដាក់លទ្ធផលនៃការវាយតម្លៃនេះជូនអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យ និងសម្រេច។

អាស្រ័យហេតុនេះ បើអ្នកទទួលការណាមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យនៅសាលារាជធានី ខេត្តដែលខ្លួនធ្វើអាជីវកម្មអចិន្ត្រៃយ៍។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការក្នុងឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យជាថ្មីឡើងវិញដែរ។ ពាក្យសុំចុះឈ្មោះអ្នកទទួលការអាចរកបាននៅទីចាត់ការផែនការ និងវិនិយោគនៃសាលារាជធានី ខេត្ត ដោយឥតគិតថ្លៃ ឬអាចទាញយកពីគេហទំព័រ គ.ជ.អ.ប (www.ncdd.gov.kh)។

ការប្រកាសជូនដំណឹងស្ដីពីការដាក់ពាក្យចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដោយឡែកសម្រាប់រាជធានី ខេត្តនីមួយៗមានបិទផ្សាយនៅលើក្ដារព័ត៌មានរបស់សាលារាជធានី ខេត្ត រៀងៗខ្លួន។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**
**អនុប្រធាន**

**ចាន់ ចំរើន**